**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**គណៈកម្មាធិការប្រឡងថ្នាក់ជាតិ**
**សម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល**

លេខ:.....០០២........./២៥ គបជ

ថ្ងៃសុក្រ ១២កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្រឡងថ្នាក់ជាតិចូលរៀន ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន សម្រាប់កម្រិតបរិញ្ញាបត្រ និងថ្នាក់ឆ្នាំទី១ សម្រាប់កម្រិតបរិញ្ញាបត្ររង នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល ឆ្នាំសិក្សា ២០២៤-២០២៥

គណៈកម្មាធិការប្រឡងថ្នាក់ជាតិសម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល សូមជម្រាបដល់គ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល និងបេក្ខជនដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិទាំងអស់ឱ្យបានជ្រាបថា គណៈកម្មាធិការប្រឡងថ្នាក់ជាតិនឹងធ្វើការរៀបចំការប្រឡងថ្នាក់ជាតិចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន សម្រាប់កម្រិតបរិញ្ញាបត្រ និងថ្នាក់ឆ្នាំទី១ សម្រាប់កម្រិតបរិញ្ញាបត្ររង នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល ក្នុងឆ្នាំសិក្សា២០២៤-២០២៥ ខាងមុខនេះ តាមចំនួន និងលក្ខខណ្ឌដូចខាងក្រោម៖

**១. លក្ខខណ្ឌនៃការប្រឡងជ្រើសរើស៖**

បេក្ខជនត្រូវមាន៖

- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬវិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាទុតិយភូមិ/ព្រឹត្តប័ត្រពិន្ទុនៃការប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចេញដោយនាយកដ្ឋានជំនាញ នៃក្រសួងអប់រំ យុវជន និងកីឡា ឬមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត ឬ
- សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ ដែលទទួលស្គាល់ដោយក្រសួងធម្មការ និងសាសនា
- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬវិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាទុតិយភូមិចេញដោយគ្រឹះស្ថានសិក្សាមកពីក្នុង/ក្រៅប្រទេស ដែលសមមូលដោយក្រសួងអប់រំ យុវជន និងកីឡា។ ចំពោះសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិដែលចេញដោយសាលាអន្តរជាតិ ស៊ី អាយ អេ ហ្វឹសត៍ សាលាអន្តរជាតិឡូហ្គោស សាលាអន្តរជាតិអាស៊ានហូប និងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិដែលចេញដោយក្រសួងអប់រំជាតិបារាំងទាំងពីរប្រភេទ គឺសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណេះទូទៅ (Diplôme du baccalauréat Général) និងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបច្ចេកវិទ្យា (Diplôme du baccalauréat technologique) មិនតម្រូវឱ្យសមមូលទេ។

សម្គាល់៖

- បេក្ខជនមិនអាចយកសញ្ញាបត្របរិញ្ញាបត្ររង នៃជំនាញណាមួយ ដើម្បីដាក់ពាក្យសុំចូលរួមប្រឡងថ្នាក់ជាតិចូលរៀន ក្នុងវិស័យសុខាភិបាលបានឡើយ
- ដំណើរការ នៃការប្រឡងប្រព្រឹត្តទៅជាភាសាខ្មែរ
- បេក្ខជនដែលបានប្រឡងថ្នាក់ជាតិជាប់ចូលរៀនសម្រាប់វិស័យសុខាភិបាល ក្នុងឆ្នាំសិក្សា២០២៤-២០២៥ មានសិទ្ធិទទួលបានអាហារូបករណ៍ចំពោះតែបេក្ខជនដែលបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នាសម័យប្រឡងថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២៤ និងមិនទាន់ទទួលបានអាហារូបករណ៍ជំនាញដទៃទៀត តែប៉ុណ្ណោះ លើកលែងតែនិស្សិតដែលប្រឡងថ្នាក់ជាតិជាប់ចូលរៀន នៅតាមសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ បាត់ដំបង កំពត កំពង់ចាម និងស្ទឹងត្រែង។ ចំពោះនិស្សិតដែលបានប្រឡងជាប់នឹងទទួលអាហារូបករណ៍ជំនាញដទៃទៀតរួចហើយមានសិទ្ធិចូលរៀនតាមរយៈការបង់ថ្លៃសិក្សា។ គណៈកម្មាធិការប្រឡងថ្នាក់ជាតិសម្រាប់ការបណ្ដុះបណ្ដាលក្នុងវិស័យសុខាភិបាលនឹងធ្វើការប្រកាសលទ្ធផលតែបេក្ខជនដែលប្រឡងជាប់តែប៉ុណ្ណោះ។ ដោយឡែក ចំពោះការជ្រើសរើសផ្ដល់អាហារូបករណ៍ ដល់និស្សិតដែលប្រឡងថ្នាក់ជាតិជាប់ចូលរៀន នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលនឹងធ្វើឡើងដោយគណៈកម្មការដោយឡែកមួយរបស់សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល។ ការជ្រើសរើសផ្ដល់អាហារូបករណ៍នេះត្រូវគោរពទៅតាមលក្ខខណ្ឌរបស់ក្រសួងអប់រំ យុវជន និងកីឡា។
- បេក្ខជនមានសិទ្ធិជ្រើសរើសមុខជំនាញ និងជ្រើសរើសគ្រឹះស្ថានបណ្ដុះបណ្ដាលទៅតាមអាទិភាព ដែលខ្លួនចង់ចូលរៀន។

## ២. ចំនួនជ្រើសរើស៖

លទ្ធផលជាប់ស្ថាពរ នៃការប្រឡងនឹងជ្រើសយកបេក្ខជនដែលមានពិន្ទុមធ្យមភាគសរុប (Moyenne générale) កំណត់ជាប់តាមលំដាប់ពិន្ទុពីខ្ពស់មកទាប តាមចំនួនកំណត់អតិបរមា នៃមុខជំនាញ និងតាមអាទិភាពរបស់បេក្ខជនដែលបានដាក់ពាក្យនៅតាមគ្រឹះស្ថានបណ្ដុះបណ្ដាល។

យោងតាមប្រកាសលេខ ០៣១៩ អបស.អធម.ប្រក ចុះថ្ងៃសុក្រ ៨កើត ខែកត្ដិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកំណត់ចំនួននិស្សិតមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឱ្យចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ឬឆ្នាំទី១ នៅតាមគ្រឹះស្ថានបណ្ដុះបណ្ដាលក្នុងវិស័យសុខាភិបាលសម្រាប់ឆ្នាំសិក្សា២០២៤-២០២៥ របស់ក្រសួងសុខាភិបាល មានចំនួនសរុប ១១ ១៦៥នាក់ ដោយបែងចែកដូចខាងក្រោម៖

ក. កម្រិតបរិញ្ញាបត្រ

- ថ្នាក់វេជ្ជបណ្ឌិតទូទៅ៖ សរុបចំនួន ៩៥០នាក់ ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្ដុះបណ្ដាលដូចខាងក្រោម៖

  - សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចំនួន ៣៥០នាក់
    (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្ដល់អាហារូបករណ៍)
  - វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ចំនួន ១៥០នាក់
    (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្ដល់អាហារូបករណ៍យោធា)
  - សាកលវិទ្យាល័យអន្តរជាតិ(ភ្នំពេញ) ចំនួន ២០០នាក់

- សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ចំនួន ១៥០នាក់
- សាកលវិទ្យាល័យន័រតុន ចំនួន ១០០នាក់

❖ ថ្នាក់បរិញ្ញាបត្រឱសថ៖ សរុបចំនួន ១០១០នាក់ ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដូចខាងក្រោម៖

- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចំនួន ៣០០នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍)
- វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ចំនួន ១៥០នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍យោធា)
- សាកលវិទ្យាល័យអន្តរជាតិ(ភ្នំពេញ) ចំនួន ១៥០នាក់
- សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ចំនួន ១៥០នាក់
- សាកលវិទ្យាល័យន័រតុន ចំនួន ១០០នាក់
- វិទ្យាស្ថានបូលីណូ កំពង់ឆ្នាំង ចំនួន ៦០នាក់
- វិទ្យាស្ថានវិទ្យាសាស្ត្រអាស៊ី ចំនួន ១០០នាក់

❖ ថ្នាក់ទន្តបណ្ឌិតទូទៅ៖ សរុបចំនួន ៥១០នាក់ ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដូចខាងក្រោម៖

- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចំនួន ១២០នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍)
- វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ចំនួន ៦០នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍យោធា)
- សាកលវិទ្យាល័យអន្តរជាតិ(ភ្នំពេញ) ចំនួន ៩០នាក់
- សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ចំនួន ៩០នាក់
- សាកលវិទ្យាល័យន័រតុន ចំនួន ៦០នាក់
- វិទ្យាស្ថានបូលីណូ កំពង់ឆ្នាំង ចំនួន ៤០នាក់
- វិទ្យាស្ថានវិទ្យាសាស្ត្រអាស៊ី ចំនួន ៥០នាក់

❖ ថ្នាក់បរិញ្ញាបត្រគិលានុបដ្ឋាក៖ សរុបចំនួន ៨៧០នាក់ ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដូចខាងក្រោម៖

- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចំនួន ២០០នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍)
- វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ចំនួន ៥០នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍យោធា)
- សាកលវិទ្យាល័យអន្តរជាតិ(ភ្នំពេញ) ចំនួន ៨០នាក់
- សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ចំនួន ៨០នាក់
- សាកលវិទ្យាល័យចេនឡាភ្នំពេញ ចំនួន ៤០នាក់
- សាកលវិទ្យាល័យឡាយហ្វ ចំនួន ៤០នាក់
- សាកលវិទ្យាល័យន័រតុន ចំនួន ៥០នាក់
- វិទ្យាស្ថានបូលីណូ កំពង់ឆ្នាំង ចំនួន ៤០នាក់
- សាកលវិទ្យាល័យកំពង់ចាម ចំនួន ៤០នាក់

- សាកលវិទ្យាល័យអង្គរ ចំនួន ៥០នាក់
- សាកលវិទ្យាល័យអន្តរជាតិសាខាខេត្តបាត់ដំបង ចំនួន ៥០នាក់
- វិទ្យាស្ថានវិទ្យាសាស្ត្រអាស៊ី ចំនួន ៥០នាក់
- មហាវិទ្យាល័យ គិលានុបដ្ឋាក រ៉ូជ៉ុងកម្ពុជា ចំនួន ១០០នាក់

❖ ថ្នាក់បរិញ្ញាបត្រឆ្មប៖ សរុបចំនួន ៤៩៥នាក់ ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដូចខាងក្រោម៖

- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចំនួន ៦៥នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍)
- វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ចំនួន ៥០នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍យោធា)
- សាកលវិទ្យាល័យអន្តរជាតិ(ភ្នំពេញ) ចំនួន ៤០នាក់
- សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ចំនួន ៤០នាក់
- សាកលវិទ្យាល័យចេនឡាភ្នំពេញ ចំនួន ៤០នាក់
- សាកលវិទ្យាល័យឡាយហ្វ ចំនួន ៤០នាក់
- វិទ្យាស្ថានបូលីណូ កំពង់ឆ្នាំង ចំនួន ៤០នាក់
- សាកលវិទ្យាល័យកំពង់ចាម ចំនួន ៤០នាក់
- សាកលវិទ្យាល័យន័រតុន ចំនួន ៤០នាក់
- សាកលវិទ្យាល័យអន្តរជាតិសាខាខេត្តបាត់ដំបង ចំនួន ៥០នាក់
- វិទ្យាស្ថានវិទ្យាសាស្ត្រអាស៊ី ចំនួន ៥០នាក់

❖ ថ្នាក់បរិញ្ញាបត្រសុខភាពសាធារណៈ៖ សរុបចំនួន៤០នាក់ ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដូចខាងក្រោម៖

- សាកលវិទ្យាល័យអន្តរជាតិ(ភ្នំពេញ) ចំនួន ៤០នាក់

❖ ថ្នាក់បរិញ្ញាបត្រព្យាបាលដោយចលនា៖ សរុបចំនួន១២០នាក់ ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដូចខាងក្រោម៖

- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចំនួន ១២០នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍)

❖ ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្របច្ចេកទេសមន្ទីរពិសោធន៍វេជ្ជសាស្ត្រ៖ សរុបចំនួន៦០នាក់ ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដូចខាងក្រោម៖

- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចំនួន ៦០នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍)

ខ.កម្រិតបរិញ្ញាបត្ររង

❖ ថ្នាក់បរិញ្ញាបត្ររងគិលានុបដ្ឋាក៖ សរុបចំនួន៣០៦០នាក់ ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដូចខាងក្រោម៖

- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចំនួន ៣០០នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍)
- វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ចំនួន ៣០០នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍យោធា)

- សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ បាត់ដំបង ចំនួន ១៦០នាក់
- សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ កំពង់ចាម ចំនួន ២០០នាក់
- សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ កំពត ចំនួន ២០០នាក់
- សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ ស្ទឹងត្រែង ចំនួន ២០០នាក់
- សាកលវិទ្យាល័យអន្តរជាតិ(ភ្នំពេញ) ចំនួន ២០០នាក់
- សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ចំនួន ២០០នាក់
- សាកលវិទ្យាល័យន័រតុន ចំនួន ១០០នាក់
- សាកលវិទ្យាល័យចេនឡាភ្នំពេញ ចំនួន ២០០នាក់
- សាកលវិទ្យាល័យឡាយហ្វ ចំនួន ១០០នាក់
- សាកលវិទ្យាល័យកំពង់ចាម ចំនួន ១៥០នាក់
- វិទ្យាស្ថានបូលីណូ កំពង់ឆ្នាំង ចំនួន ១៥០នាក់
- វិទ្យាស្ថានវិទ្យាសាស្ត្រអាស៊ី ចំនួន ២០០នាក់
- សាកលវិទ្យាល័យអង្គរ ចំនួន ២០០នាក់
- វិទ្យាស្ថានវិទ្យាសាស្ត្រថៃទាំបាត់ដំបង ចំនួន ១០០នាក់
- សាកលវិទ្យាល័យអន្តរជាតិសាខាខេត្តបាត់ដំបង ចំនួន ១០០នាក់

❖ ថ្នាក់បរិញ្ញាបត្ររងឆ្មប៖ សរុបចំនួន ២២៧០នាក់ ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដូចខាងក្រោម៖

- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចំនួន ២០០នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍)
- វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ចំនួន ១៧០នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍យោធា)
- សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ បាត់ដំបង ចំនួន ១០០នាក់
- សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ កំពង់ចាម ចំនួន ២០០នាក់
- សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ កំពត ចំនួន ២០០នាក់
- សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ ស្ទឹងត្រែង ចំនួន ១៥០នាក់
- សាកលវិទ្យាល័យអន្តរជាតិ (ភ្នំពេញ) ចំនួន ១៥០នាក់
- សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ចំនួន ១៥០នាក់
- សាកលវិទ្យាល័យន័រតុន ចំនួន ១០០នាក់
- សាកលវិទ្យាល័យចេនឡាភ្នំពេញ ចំនួន ១៥០នាក់
- សាកលវិទ្យាល័យឡាយហ្វ ចំនួន ៥០នាក់
- សាកលវិទ្យាល័យកំពង់ចាម ចំនួន ១០០នាក់
- វិទ្យាស្ថានបូលីណូ កំពង់ឆ្នាំង ចំនួន ១០០នាក់
- វិទ្យាស្ថានវិទ្យាសាស្ត្រអាស៊ី ចំនួន ១៥០នាក់
- សាកលវិទ្យាល័យអង្គរ ចំនួន ១០០នាក់
- វិទ្យាស្ថានវិទ្យាសាស្ត្រថៃទាំបាត់ដំបង ចំនួន ១០០នាក់
- សាកលវិទ្យាល័យអន្តរជាតិសាខាខេត្តបាត់ដំបង ចំនួន ១០០នាក់

❖ ថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសមន្ទីរពិសោធន៍៖ សរុបចំនួន៩៨០នាក់ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្តុះបណ្តាល ដូចខាងក្រោម៖

- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចំនួន ១៥០នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍)
- វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ចំនួន ៨០នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍យោធា)
- សាកលវិទ្យាល័យអន្តរជាតិ(ភ្នំពេញ) ចំនួន ១៥០នាក់
- សាកលវិទ្យាល័យពុទ្ធិសាស្ត្រ ចំនួន ១០០នាក់
- សាកលវិទ្យាល័យន័រតុន ចំនួន ១០០នាក់
- សាកលវិទ្យាល័យចេនឡាភ្នំពេញ ចំនួន ១០០នាក់
- សាកលវិទ្យាល័យកំពង់ចាម ចំនួន ៥០នាក់
- វិទ្យាស្ថានបូលីណូ កំពង់ឆ្នាំង ចំនួន ១០០នាក់
- វិទ្យាស្ថានវិទ្យាសាស្ត្រអាស៊ី ចំនួន ១០០នាក់
- សាកលវិទ្យាល័យអន្តរជាតិសាខាខេត្តបាត់ដំបង ចំនួន ៥០នាក់

❖ ថ្នាក់បរិញ្ញាបត្ររងទន្តគិលានុបដ្ឋាក៖ សរុបចំនួន៤៧០នាក់ ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដូចខាងក្រោម៖

- សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ កំពង់ចាម ចំនួន ១០០នាក់
- សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ កំពត ចំនួន ៤០នាក់
- សាកលវិទ្យាល័យអន្តរជាតិ (ភ្នំពេញ) ចំនួន ៨០នាក់
- សាកលវិទ្យាល័យកំពង់ចាម ចំនួន ៨០នាក់
- វិទ្យាស្ថានបូលីណូ កំពង់ឆ្នាំង ចំនួន ៨០នាក់
- សាកលវិទ្យាល័យអន្តរជាតិសាខាខេត្តបាត់ដំបង ចំនួន ៤០នាក់
- វិទ្យាស្ថានវិទ្យាសាស្ត្រអាស៊ី ចំនួន ៥០នាក់

❖ ថ្នាក់បរិញ្ញាបត្ររងព្យាបាលដោយចលនា៖ សរុបចំនួន១៧០នាក់ ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដូចខាងក្រោម៖

- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចំនួន ១២០នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍)
- សាកលវិទ្យាល័យអន្តរជាតិ (ភ្នំពេញ) ចំនួន ៥០នាក់

❖ ថ្នាក់បរិញ្ញាបត្ររងបច្ចេកទេសវិទ្យុសាស្ត្រ៖ សរុបចំនួន១៦០នាក់ ដោយធ្វើការបែងចែកទៅតាមគ្រឹះស្ថានបណ្តុះបណ្តាលដូចខាងក្រោម៖

- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចំនួន ១២០នាក់
  (ចំនួននេះរាប់បញ្ចូលទាំងចំនួនដែលត្រូវផ្តល់អាហារូបករណ៍)
- វិទ្យាស្ថានបូលីណូ កំពង់ឆ្នាំង ចំនួន ៤០នាក់

បញ្ជាក់៖

- បេក្ខជនអាចជ្រើសរើសយកគ្រឹះស្ថានបណ្តុះបណ្តាលបានចំនួនពីរ គឺអាទិភាពទី១ និងទី២
- បេក្ខជនដែលមានពិន្ទុមធ្យមភាគសរុបកំណត់ជាប់ ពុំមានសិទ្ធិតវ៉ាសុំចូលរៀននៅតាមគ្រឹះស្ថានបណ្តុះបណ្តាលណាមួយលើសពីចំនួនកំណត់អតិបរមានៅតាមគ្រឹះស្ថាននីមួយៗ និងខុសពីជម្រើសរបស់ខ្លួនឡើយ

- គ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាលទាំងអស់ខាងលើ ពុំមានសិទ្ធិតវ៉ាសុំយកនិស្សិតបន្ថែមដើម្បីបង្គ្រប់ចំនួនបែងចែកឡើយ ក្នុងករណីដែលនិស្សិតបានប្រឡងថ្នាក់ជាតិជាប់ តែពុំបានដាក់ពាក្យស្នើសុំចូលរៀននៅតាមគ្រឹះស្ថានបណ្តុះបណ្តាលទាំងនោះ
- គណៈកម្មាធិការប្រឡងថ្នាក់ជាតិនឹងមិនធ្វើការជ្រើសរើសនិស្សិតបន្ថែមដើម្បីបំពេញចំនួនកំណត់តាមគ្រឹះស្ថានបណ្តុះបណ្តាលខាងលើ ក្នុងករណីដែលនិស្សិតប្រឡងជាប់តែពុំបានធ្វើការជ្រើសរើសចូលរៀននៅគ្រឹះស្ថានបណ្តុះបណ្តាលទាំងនោះ
- បេក្ខជនត្រូវបង់ថ្លៃសម្រាប់រៀបចំការប្រឡងថ្នាក់ជាតិចូលរៀន **ចំនួន ១២០ ០០០រៀល** (មួយរយម្ភៃពាន់រៀលគត់) ក្នុងមួយនាក់។

៣-មុខវិជ្ជា និងរយៈពេលប្រឡង៖

➢ កម្រិតបរិញ្ញាបត្រ

| | |
|---|---|
| • ជីវវិទ្យា | រយៈពេលធ្វើ ១ ម៉ោង ៣០ នាទី |
| • គីមីវិទ្យា | រយៈពេលធ្វើ ១ ម៉ោង ៣០ នាទី |
| • គណិតវិទ្យា | រយៈពេលធ្វើ ២ ម៉ោង ០០ នាទី |

➢ កម្រិតបរិញ្ញាបត្ររង

| | |
|---|---|
| • ជីវវិទ្យា | រយៈពេលធ្វើ ១ ម៉ោង ០០ នាទី |
| • គីមីវិទ្យា | រយៈពេលធ្វើ ១ ម៉ោង ០០ នាទី |
| • គណិតវិទ្យា | រយៈពេលធ្វើ ១ ម៉ោង ០០ នាទី |

វិញ្ញាសាយកតាមកម្មវិធីសិក្សាថ្នាក់ទី១២ របស់ក្រសួងអប់រំ យុវជន និងកីឡា។

៤- កាលបរិច្ឆេទចុះឈ្មោះប្រឡង និងការដាក់ពាក្យ

❖ កាលបរិច្ឆេទចុះឈ្មោះប្រឡង៖

- សម្រាប់កម្រិតបរិញ្ញាបត្រ រួមមាន៖ ថ្នាក់វេជ្ជបណ្ឌិតទូទៅ ទន្តបណ្ឌិត បរិញ្ញាបត្រឱសថ បរិញ្ញាបត្រគិលានុបដ្ឋាក បរិញ្ញាបត្រឆ្មប បរិញ្ញាបត្រសុខភាពសាធារណៈ បរិញ្ញាបត្រព្យាបាលដោយចលនា និងបរិញ្ញាបត្រវិទ្យាសាស្ត្របច្ចេកទេសមន្ទីរពិសោធន៍វេជ្ជសាស្ត្រ ចាប់ផ្តើមទទួលពាក្យចាប់ពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៥ វេលាម៉ោង១៧:០០នាទី ជាកំហិត។
- សម្រាប់កម្រិតបរិញ្ញាបត្ររង រួមមាន៖ ថ្នាក់បរិញ្ញាបត្ររងគិលានុបដ្ឋាក បរិញ្ញាបត្ររងឆ្មប បរិញ្ញាបត្ររងបច្ចេកទេសមន្ទីរពិសោធន៍ បរិញ្ញាបត្ររងទន្តគិលានុបដ្ឋាក បរិញ្ញាបត្ររងព្យាបាលដោយចលនា និងបរិញ្ញាបត្ររងបច្ចេកទេសវិទ្យុសាស្ត្រ ចាប់ផ្តើមទទួលពាក្យចាប់ពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៥ វេលាម៉ោង១៧:០០នាទី ជាកំហិត។

❖ ការដាក់ពាក្យប្រឡងតាមរយៈប្រព័ន្ធអនឡាញ៖

- បេក្ខជនត្រូវមានអាសយដ្ឋានអ៊ីម៉ែល និងលេខទូរសព្ទដែលប្រើប្រាស់គេឡក្រោមដើម្បីចុះឈ្មោះចូលប្រព័ន្ធ
- បេក្ខជនអាចស្កេន QR Code ខាងក្រោម ឬចូលទៅកាន់គេហទំព័រ https://medical-exam.poscar.cloud/ ដើម្បីបំពេញព័ត៌មានសុំសិទ្ធិប្រឡង និងស្កេនបញ្ចូលឯកសារតម្រូវសម្រាប់ការដាក់ពាក្យ

- បេក្ខជននឹងទទួលព័ត៌មានអំពីការចុះឈ្មោះប្រឡងរបស់ខ្លួនតាមរយៈអាសយដ្ឋានអ៊ីម៉ែលដែលបានប្រើប្រាស់ ឬតេឡេក្រាម(ករណីបើមាន)។
- ក្នុងករណីមានចម្ងល់ពាក់ព័ន្ធនឹងការចុះឈ្មោះ បេក្ខជនអាចទាក់ទងមកកាន់ទូរសព្ទលេខ ០១៥ ៩០២ ៥៤៣ ឬ ០៧៦ ២៣ ៥៤ ៣២៥ ឬ ០៧១ ២៣ ៥៤ ២០៤។

❖ ឯកសារតម្រូវ ត្រូវស្កេនពីឯកសារដើម៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។ ក្នុងករណីមិនមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ បេក្ខជនត្រូវមានប័ណ្ណសម្គាល់ខ្លួនសិស្សថ្នាក់ទី១២
- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬវិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាទុតិយភូមិ/ព្រឹត្តប័ត្រពិន្ទុនៃការប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចេញដោយនាយកដ្ឋានជំនាញ នៃក្រសួងអប់រំ យុវជន និងកីឡា ឬមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត ឬ
- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬវិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាទុតិយភូមិ ដែលសមមូលដោយក្រសួងអប់រំ យុវជន និងកីឡា ច្បាប់ដើម។ សញ្ញាបត្រ ឬវិញ្ញាបនបត្រនេះចេញដោយគ្រឹះស្ថានសិក្សាមកពីក្នុង ឬក្រៅប្រទេស ឬ
- សម្រាប់បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនាសម័យប្រឡងថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២៤៖
  - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។ ក្នុងករណីមិនមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ បេក្ខជនត្រូវមានប័ណ្ណសម្គាល់ខ្លួនសិស្សថ្នាក់ទី១២
  - សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬវិញ្ញាបនបត្របណ្តោះអាសន្នមធ្យមសិក្សាទុតិយភូមិ/ព្រឹត្តប័ត្រពិន្ទុនៃការប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចេញដោយនាយកដ្ឋានជំនាញ នៃក្រសួងអប់រំ យុវជន និងកីឡា ឬមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត
- រូបថតចំពីមុខ គ្មានពាក់មួក គ្មានពាក់វ៉ែនតា ទំហំ ៤x៦ (ផ្ទៃខាងក្រោយពណ៌ស ឬផ្ទៃមេឃ) ថតថ្មី០៦ខែចុងក្រោយ។

សម្គាល់៖

- ចំពោះនិស្សិតដែលធ្លាប់បានលុបឈ្មោះចេញពីបញ្ជីឈ្មោះនិស្សិតប្រឡងថ្នាក់ជាតិជាប់ចូលរៀននាពេលកន្លងមក មិនអនុញ្ញាតឱ្យដាក់ពាក្យចូលរួមប្រឡងថ្នាក់ជាតិចូលរៀនទៀតឡើយ
- បេក្ខសមណៈ(ជាបព្វជិត ឬព្រះសង្ឃ) នៅពេលប្រឡងជាប់ត្រូវលាចាកសិក្ខាបទ។

### ៦-កាលបរិច្ឆេទ និងមណ្ឌលប្រឡង

### ក.កាលបរិច្ឆេទប្រឡង៖

### ក.១.សម្រាប់កម្រិតបរិញ្ញាបត្រ៖

ការប្រឡងនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៥ ដែលមានកម្មវិធីដូចខាងក្រោម៖

❖ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៥៖

- ម៉ោង១៣:៣០នាទី ដល់ម៉ោង១៥:០០នាទី៖ ប្រឡងមុខវិជ្ជាជីវវិទ្យា
- ម៉ោង១៥:៣០នាទី ដល់ម៉ោង១៧:០០នាទី៖ ប្រឡងមុខវិជ្ជាគីមីវិទ្យា

❖ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៥៖

- ម៉ោង១៤:០០នាទី ដល់ម៉ោង១៦:០០នាទី៖ ប្រឡងមុខវិជ្ជាគណិតវិទ្យា

### ក.២.សម្រាប់កម្រិតបរិញ្ញាបត្ររង៖

ការប្រឡងនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៦ ដល់ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៥ ដែលមានកម្មវិធីដូចខាងក្រោម៖

❖ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៥៖

- ម៉ោង១៣:៣០នាទី ដល់ម៉ោង១៤:៣០នាទី៖ ប្រឡងមុខវិជ្ជាជីវវិទ្យា
- ម៉ោង១៥:៣០នាទី ដល់ម៉ោង១៦:៣០នាទី៖ ប្រឡងមុខវិជ្ជាគីមីវិទ្យា

❖ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៥៖

- ម៉ោង១៤:០០នាទី ដល់ម៉ោង១៥:០០នាទី៖ ប្រឡងមុខវិជ្ជាគណិតវិទ្យា

ខ.មណ្ឌលប្រឡង៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

- សំណុំលិខិតស្នើសុំចូលរួមប្រឡងថ្នាក់ជាតិចូលរៀន និងព័ត៌មានផ្សេងៗទៀត សូមទាក់ទងនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល។
- *គណៈកម្មាធិការប្រឡងថ្នាក់ជាតិសូមរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរកាលបរិច្ឆេទប្រឡង និងមណ្ឌលប្រឡងក្នុងករណីមានការចាំបាច់។*

បញ្ជាក់៖

១.និស្សិតដែលមានបំណងដាក់ពាក្យសុំចូលរួមការប្រឡងថ្នាក់ជាតិចូលរៀន មុខជំនាញក្នុងវិស័យសុខាភិបាល អាចជ្រើសរើសគ្រឹះស្ថានបណ្តុះបណ្តាល ដោយកំណត់ពីអាទិភាពជ្រើសរើសយកគ្រឹះស្ថានបណ្តុះបណ្តាលដែលខ្លួនមានបំណងចូលរៀន ដូចខាងក្រោម៖

ក. កម្រិតបរិញ្ញាបត្រ៖

- និស្សិតអាចជ្រើសរើសយកគ្រឹះស្ថានបណ្តុះបណ្តាលចំនួន២ ដោយកំណត់ឱ្យច្បាស់លាស់ពីអាទិភាពទី១ និងទី២ ចំពោះផ្នែកវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តវេទសាស្ត្រ បរិញ្ញាបត្រគិលានុបដ្ឋាក និងបរិញ្ញាបត្រឆ្មប
- ថ្នាក់បរិញ្ញាបត្រសុខភាពសាធារណៈ៖ និស្សិតអាចជ្រើសរើសយកគ្រឹះស្ថានបណ្តុះបណ្តាលបានតែចំនួន១ ប៉ុណ្ណោះ នៅសាកលវិទ្យាល័យអន្តរជាតិ
- ថ្នាក់បរិញ្ញាបត្រព្យាបាលដោយចលនា៖ និស្សិតអាចជ្រើសរើសយកគ្រឹះស្ថានបណ្តុះបណ្តាលបានតែចំនួន១ ប៉ុណ្ណោះ នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
- ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រមន្ទីរពិសោធន៍វេជ្ជសាស្ត្រ៖ និស្សិតអាចជ្រើសរើសយកគ្រឹះស្ថានបណ្តុះបណ្តាលបានតែចំនួន១ ប៉ុណ្ណោះ នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល។

ខ.កម្រិតបរិញ្ញាបត្ររង៖

- និស្សិតអាចជ្រើសរើសយកគ្រឹះស្ថានបណ្តុះបណ្តាលចំនួន២ ដោយកំណត់ឱ្យច្បាស់លាស់ពីអាទិភាពទី១ និងទី២ ចំពោះផ្នែកបរិញ្ញាបត្ររងគិលានុបដ្ឋាក បរិញ្ញាបត្ររងឆ្មប បរិញ្ញាបត្ររងបច្ចេកទេសមន្ទីរពិសោធន៍ បរិញ្ញាបត្ររងទន្តគិលានុបដ្ឋាក បរិញ្ញាបត្ររងព្យាបាលដោយចលនា និងបរិញ្ញាបត្ររងវិទ្យុសាស្ត្រ។

២.បេក្ខជនដែលមានបំណងដាក់ពាក្យសុំចូលរួមប្រឡងថ្នាក់ជាតិចូលរៀន នៅតាមសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ បាត់ដំបង កំពង់ចាម កំពត និងស្ទឹងត្រែង អាចទទួលបានអាហារូបករណ៍ចំនួនតែ១(មួយ)កន្លែង នៃសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ ដែលខ្លួនបានដាក់ពាក្យប៉ុណ្ណោះដោយគោរពតាមមុខជំនាញ ដែលសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគទាំងបួនមាន ប៉ុន្តែបេក្ខជនអាចជ្រើសរើសអាទិភាពទី២បាន ដោយត្រូវបង់ថ្លៃសិក្សានៅតាមគ្រឹះស្ថានបណ្តុះបណ្តាលឯកជន ក្នុងករណីបេក្ខជនមិនបានប្រឡងជាប់ថ្នាក់ជាតិជ្រើសរើសចូលរៀននៅតាមសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគដែលខ្លួនបានដាក់ពាក្យ។ បេក្ខជនដែលមានបំណងទទួលបានអាហារូបករណ៍ត្រូវដាក់ពាក្យ នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគទាំងបួន។

៣.ករណីរកឃើញថាបេក្ខជនក្លែងបន្លំសញ្ញាបត្រ ឬឯកសារពាក់ព័ន្ធ ត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះនិស្សិតចូលរៀននៅតាមគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល ដែលខ្លួនបានជ្រើសរើស និងត្រូវផ្តន្ទាទោសទៅតាមច្បាប់ជាធរមាន។

៤.ករណីរកឃើញថាមានការប្រឡងជំនួស អ្នកប្រឡងជំនួសគេ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះនិស្សិតដែលខ្លួនកំពុងរៀនបច្ចុប្បន្ននិងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។ ចំពោះបេក្ខជនដែលឱ្យគេប្រឡងជួស នឹងត្រូវបានចាត់ទុកថាធ្លាក់ដោយស្វ័យប្រវត្តិហើយត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ដូចអ្នកមកប្រឡងជួសដែរ។

៥.នៅថ្ងៃប្រឡងបេក្ខជន ត្រូវយកជាប់ជាមួយខ្លួននូវបង្កាន់ដៃទទួលពាក្យ និងប័ណ្ណសម្គាល់ខ្លួនសិស្សថ្នាក់ទី១២។ ក្នុងករណីបេក្ខជនមិនមានបង្កាន់ដៃទទួលពាក្យ និងប័ណ្ណសម្គាល់ខ្លួនសិស្សថ្នាក់ទី១២នឹងមិនអនុញ្ញាតឱ្យចូលក្នុងបន្ទប់ប្រឡងឡើយ។

៦.មិនត្រូវយកចូលក្នុងមណ្ឌលប្រឡងនូវអាវុធជាតិផ្ទុះ ទូរសព្ទដៃ ឧបករណ៍អេឡិចត្រូនិចគ្រប់ប្រភេទ សៀវភៅសំណៅឯកសារ ម៉ាស៊ីនគិតលេខ នាឡិកាដែលមានម៉ាស៊ីនគិតលេខ កាតាប កាបូបយួរដៃ ថង់ សំពាត កញ្ចប់ផ្សេងៗ និងទឹកលុបពណ៌ស។

៧.បេក្ខជនដែលអនុវត្តផ្ទុយពីបទបញ្ជាផ្ទៃក្នុង សម្រាប់ការប្រឡងថ្នាក់ជាតិចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ឬថ្នាក់ឆ្នាំទី១ ក្នុងវិស័យសុខាភិបាល ត្រូវចាត់ទុកថាធ្លាក់ដោយស្វ័យប្រវត្តិ

៨. ក្នុងករណីបេក្ខជនម្នាក់ដាក់ពាក្យប្រឡងលើសពីមួយដង ក្នុងមួយសម័យប្រឡង គណៈកម្មាធិការរក្សាសិទ្ធទទួលយកនូវពាក្យសុំចុងក្រោយបង្អស់តែមួយគត់

៩.បេក្ខជនក្លែងបន្លំឯកសារគ្រប់រូបភាពត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

**ជ.គណៈកម្មាធិការប្រឡងថ្នាក់ជាតិ**
**សម្រាប់ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល**
**ប្រធាន**

**សុខ ផេង**

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រុមប្រឹក្សាសាកលវិទ្យាធិការកម្ពុជា
- សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា
- គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាលពាក់ព័ន្ធ
- ឯកសារ កាលប្បវត្តិ